KHMER

# ការជ្រើសរើសការមើលថែទាំពេញមួយថ្ងៃដែលមានគុណភាព

## ពត៌មានសំរាប់គ្រួសារ

Putting Children First®

NCAC

National Childcare Accreditation Council Inc.

### តើអ្វីទៅការមើលថែទាំពេញមួយថ្ងៃ?

ការមើលថែទាំកុមារពេញមួយថ្ងៃ ផ្តល់នូវការមើលថែទាំកុមារដែលមានមូលដ្ឋានតាមមណ្ឌលសំរាប់កុមារអាយុចាប់ពីកំណើត រហូតដល់៥ឆ្នាំ។ មណ្ឌលមើលថែទាំពេញមួយថ្ងៃធ្វើការបន្តម៉ោងដើម្បីផ្តល់ការផ្គត់ផ្គង់ដល់គ្រួសារដែលធ្វើការ ឬសិក្សា។ កុមារអាចទៅមណ្ឌលមើលថែទាំពេញមួយថ្ងៃពេញពេល ឬពាក់កណ្តាលពេលដោយអាស្រ័យទៅលើសេចក្តីត្រូវការរបស់គ្រួសារ និងភាពទំនេរនៃការមើលថែទាំ។

មណ្ឌលមើលថែទាំពេញមួយថ្ងៃផ្តល់បរិយាកាសប្រកបដោយសុវត្ថិភាពដែលកុមារអាចលេង រៀន និងពង្រីកក្នុងឆ្នាំដែលកំពុងចាប់សិក្សារបស់គេ។ ក្នុងភាពរួមដៃគូគ្នាជាមួយគ្រួសារ មណ្ឌលមើលថែទាំពេញមួយថ្ងៃផ្គត់ផ្គង់ភាពធំលូតលាស់របស់កុមារ តាមរយៈការណែនាំដែលមានការដឹងយល់ និងឱកាសដ៏ច្រើនលើសលុបសំរាប់លេង។ កុមារមានឱកាសលេងជាក្រុម និងចំណាយពេលលេងម្នាក់ឯង។

### តើខ្ញុំអាចរកបានកន្លែងមើលថែទាំពេញមួយថ្ងៃដោយរបៀបណា?

ដោយព្រោះតែគ្រួសារជាច្រើនកំពុងស្វែងរកការមើលថែទាំកុមារដែលមានគុណភាព នេះគឺជាការសំខាន់ដែលគេត្រូវចាប់ផ្តើមដំណើរការស្រាវជ្រាវឲ្យបានប្រសើរ មុននឹងត្រូវការការមើលថែទាំកុមារ។ ការនេះអនុញ្ញាតឲ្យគ្រួសារធ្វើសេចក្តីសំរេចដែលគេបានផ្តល់ពត៌មានឲ្យអំពីមណ្ឌលមើលថែទាំពេញមួយថ្ងៃដែលបំពេញទៅលើសេចក្តីត្រូវការរបស់គេបានប្រសើរបំផុត។

សាលាក្រុងតាមតំបន់ជាច្រើនផ្តល់បញ្ជីអាស័យដ្ឋាននៃកិច្ចបំរើរបស់កុមារ ដែលមានរាយឈ្មោះកិច្ចបំរើក្នុងសហគមន៍ប្រចាំតំបន់។ គ្រួសារអាចរៀបចំការទៅពិនិត្យមើលកិច្ចបំរើទាំងនោះ ដែលនឹងជួយគេក្នុងការជ្រើសរើសការមើលថែទាំរបស់គេ ហើយអនុញ្ញាតឲ្យគេពិភាក្សាអំពីកន្លែងទំនេររបស់មណ្ឌលនោះ និងដំណើរការចុះឈ្មោះកុមារ។

ដើម្បីជួយគ្រួសារស្វែងរកការមើលថែទាំ ក្រុមប្រឹក្សាជាតិទទួលស្គាល់ការមើលថែទាំកុមារជាផ្លូវការ (NCAC) មានផ្តល់ឈ្មោះកិច្ចបំរើមើលថែទាំកុមារតាមរយៈកន្លែងងាយស្រួលរកនៅតាមគេហទំព័ររបស់យើង (www.ncac.gov.au) ឬដោយទូរស័ព្ទលេខ 1300 136 554។

### តើខ្ញុំគួរព្យាយាមស្វែងរកអ្វីខ្លះ?

ជម្រើសរបស់លោកអ្នកដើម្បីកិច្ចបំរើមើលថែទាំកុមារ អាចមានឥទ្ធិពលដោយកត្តាផ្សេងៗគ្នាមួយចំនួន ហើយគ្រួសារទាំងឡាយដែលស្វែងរកការមើលថែទាំប្រកបដោយគុណភាពសំរាប់កុមារ ត្រូវបានលើកទឹកចិត្តឲ្យពិចារណានូវសំនួរប្រសើរបំផុតណាខ្លះដែលគេត្រូវសួរ ហើយតើគេត្រូវព្យាយាមស្វែងរកអ្វីខ្លះនៅក្នុងកិច្ចបំរើមើលថែទាំកុមារ។ លោកអ្នកប្រហែលជាមានបំណងចង់សួរខ្លួនឯងនូវសំនួរដូចតទៅនេះ:

- តើមណ្ឌលនោះត្រូវបានរដ្ឋទទួលស្គាល់ជាផ្លូវការឬទេ? សូមសួរគេរកមើលសញ្ញាប័ត្រទទួលស្គាល់ជាផ្លូវការ *(Certificate of Accreditation)* និង គម្រោងគុណភាព *(Quality Profile)*។
- តើអ្នកមើលថែទាំកុមារនិយាយជាមួយកុមារក្នុងលំនាំកក់ក្តៅ ហើយស្និទ្ធស្នាលឬទេ?
- តើមានដំណើរការណែនាំសំរាប់គ្រួសាររបស់ខ្ញុំឬទេ? តើនឹងមានអ្វីកើតឡើងនៅថ្ងៃដំបូងរបស់កូនខ្ញុំ?
- តើគេនឹងប្រាប់ខ្ញុំឲ្យដឹងអំពីការផ្លាស់ប្តូរបុគ្គលិកដោយបែបណា? តើខ្ញុំត្រូវនិយាយជាមួយនរណាអំពីកូនរបស់ខ្ញុំ?
- តើគេនឹងមើលខុសត្រូវកូនរបស់ខ្ញុំយ៉ាងដូចម្តេច? តើគេមើលខុសត្រូវកូនរបស់ខ្ញុំយ៉ាងដូចម្តេចនៅពេលលេងជាមួយកុមារដែលមានអាយុបង ហើយធំជាង?
- តើកូនរបស់ខ្ញុំនឹងធ្វើកិច្ចការអ្វីខ្លះ? តើគេសំរេចដាក់ឲ្យមានកិច្ចការទាំងនេះយ៉ាងដូចម្តេច?
- តើគេនឹងផ្តល់ពត៌មានត្រឡប់មកវិញអ្វីខ្លះស្តីអំពីថ្ងៃមើលថែទាំកូនរបស់ខ្ញុំ ហើយតើពត៌មាននេះនឹងត្រូវគេប្រាស្រ័យទាក់ទងជាមួយខ្ញុំតាមរបៀបណា?
- តើមានកម្មវិធីជាលាយលក្ខណ៍អក្សរដាក់បង្ហាញឬទេ? តើគ្រួសាររបស់ខ្ញុំអាចចូលរួមទាក់ទិននៅក្នុងការធ្វើគំរោងការ ហើយការឲ្យតម្លៃកម្មវិធីនោះយ៉ាងដូចម្តេច?
- តើកម្មវិធីបំពេញទៅលើសេចក្តីត្រូវការរបស់កុមារម្នាក់ៗ ឬសេចក្តីត្រូវការបន្ថែមទៀតរបស់កូនរបស់ខ្ញុំដោយរបៀបណា?
- តើគេនឹងស្តាប់គំនិត និងមតិរបស់កូនខ្ញុំ ហើយឆ្លើយតបវិញដោយរបៀបណា?
- តើប្រដាប់ប្រដាប់ក្មេងលេង គ្រឿងបរិក្ខា និងសកម្មភាពនានាដែលមាននោះបំពេញទៅលើការជ្រើសរើសរបស់កូនខ្ញុំ ហើយស្របទៅតាមចំណូលចិត្ត និងសមត្ថភាពរបស់កូនប្រុសស្រីខ្ញុំដែរឬទេ?
- តើកូនរបស់ខ្ញុំមានឱកាសដើម្បីចូលរួមនៅក្នុងសកម្មភាពនានាដែលគេអាចរុករកកិច្ចការប្រចាំជីវិតពិតឬទេ? ឧទាហរណ៍ អនាម័យផ្ទាល់ខ្លួន និងពេលបរិភោគចំណីអាហារ។
- តើមានកន្លែងសំរាប់កូនរបស់ខ្ញុំ ដើម្បីចូលរួមនៅក្នុងការលេងដែលមានសំឡេងអ៊ូអរ ព្រមទាំងកន្លែងសំរាប់លេងស្ងៀមស្ងាត់ដែរឬទេ?
- តើបរិយាកាសខាងក្នុង និងខាងក្រៅមណ្ឌល និងគ្រឿងបរិក្ខាគួរឲ្យចាប់អារម្មណ៍មានសន្តិសុខ សុវត្ថិភាព ហើយល្អស្អាតឬទេ?
- តើមានគោលការណ៍ណែនាំផ្នែកអាកប្បកិរិយាអ្វីខ្លះ ហើយតើអ្នកមើលថែទាំចាត់ចែងដំណោះស្រាយស្ថានភាពដែលកុមារកំពុងឈ្លោះគ្នា យំ ឬមិនសហប្រតិបត្តិការគ្នាយ៉ាងដូចម្តេចដែរ?
- តើអ្នកណាទទួលខុសត្រូវចំពោះការផ្តល់ម្ហូបអាហារ និងភេសជ្ជៈដល់កូនរបស់ខ្ញុំ? តើម្ហូបអាហារដែលផ្តល់ឲ្យនោះមានគ្រប់គ្រាន់ ហើយមានសារជាតិធ្វើឲ្យធំធាត់ដែរឬទេ? តើគេនឹងផ្តល់តម្រូវការផ្នែកតមម្ហូបអាហារពិសេសរបស់កូនខ្ញុំយ៉ាងដូចម្តេចដែរ?
- តើមានពត៌មានជាលាយលក្ខណ៍អក្សរស្តីអំពីគោលការណ៍ និងទម្រង់ការសំរាប់គ្រួសារឬទេ? តើគ្រួសាររបស់ខ្ញុំអាចប្រើប្រាស់ពត៌មាននេះដោយបែបណា?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើកូនរបស់ខ្ញុំត្រូវការថ្នាំពេទ្យ? ចុះប្រសិនបើកូនរបស់ខ្ញុំធ្លាក់ខ្លួនឈឺ ឬមានគ្រោះថ្នាក់ក្នុងកាលកំពុងមើលថែទាំ?
- តើនរណាទទួលខុសត្រូវចំពោះការផ្តល់កន្ទបសំរាប់កូនខ្ញុំ? តើកន្លែងផ្លាស់ប្តូរកន្ទបស្អាតឬទេ? តើមានដាក់បង្ហាញទម្រង់ការផ្លាស់ប្តូរកន្ទបឬទេ?
- តើគេនឹងជួយបង្រៀនកូនរបស់ខ្ញុំឲ្យទៅបង្គន់ដោយរបៀបណា?
- តើគេនឹងផ្តល់ពត៌មានឲ្យខ្ញុំបានដឹងអំពីរបៀបរបបញាំុរៀងៗខ្លួន និងការទម្លាប់គេងរបស់កូនខ្ញុំយ៉ាងដូចម្តេច?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើកូនរបស់ខ្ញុំនៅបំបៅដប ឬនៅបំបៅដោះ?
- តើការរៀបចំគេងសំរាប់កូនរបស់ខ្ញុំមានអ្វីខ្លះ? តើនឹងមានអ្វីកើតឡើងប្រសិនបើកូនរបស់ខ្ញុំមិនចង់គេង?

© National Childcare Accreditation Council Inc - June 2005

សូមបើកទៅទំព័រម្ខាងទៀត ->

## តើអ្វីទៅប្រព័ន្ធកែលំអគុណភាព និងការទទួលស្គាល់ជាផ្លូវការ (QIAS)?

QIAS មានបំណងផ្តល់ដល់កុមារនៅក្នុងការមើលថែទាំពេញមួយថ្ងៃពេញទូទាំងប្រទេសអូស្ត្រាលី នូវការមើលថែទាំដែលមានគុណភាពដែលជម្រុញការរៀនសូត្រ និងការធំលូតលាស់របស់គេនៅក្នុងឆ្នាំដំបូងដ៏សំខាន់របស់គេ។

គោលបំណងដ៏ទូលំទូលាយរបស់ QIAS គឺឲ្យបានច្បាស់ប្រាកដថា កុមារនៅក្នុងការមើលថែទាំពេញមួយថ្ងៃមានការជំរុញទឹកចិត្ត បទពិសោធន៍វិជ្ជមានដែលពង្រីកគ្រប់ទាំងទិដ្ឋភាពនៃការចំរើនធំធាត់របស់គេ។ គេធ្វើដូច្នេះដោយកំណត់គុណភាពនៅក្នុងការមើលថែទាំពេញមួយថ្ងៃ ហើយផ្តល់របៀបមួយដើម្បីវាស់ស្ទង់គុណភាពនៃការមើលថែទាំ។

កិច្ចបំរើដែលបំពេញខ្នាតគំរូនានារបស់ QIAS ត្រូវបានទទួលស្គាល់ជាផ្លូវការដោយ NCAC ហើយបានទទួល សញ្ញាប័ត្រនៃការទទួលស្គាល់ជាផ្លូវការ *(Certificate of Accreditation)*ដែលគេត្រូវដាក់បង្ហាញនៅតាមទីកន្លែងដែលអាចមើលឃើញច្បាស់។ គេក៏បានទទួល សញ្ញាប័ត្រគំរោងគុណភាព *(Quality Profile Certificate)* ផងដែរដែលបង្ហាញប្រាប់អំពីការសំរេចជោគជ័យរបស់កិច្ចបំរើ ទល់នឹងកន្លែងគុណភាពនីមួយៗ។ គ្រួសារអាចស្នើសុំមើលសញ្ញាប័ត្រនេះ។

ខ្នាតគំរូដើម្បីឲ្យបានទទួលស្គាល់ជាផ្លូវការ គឺផ្អែកទៅលើកន្លែងគុណភាពទាំង៧នៃការមើលថែទាំដែលប្រាកដឲ្យបានច្បាស់ថា កិច្ចបំរើកំពុងផ្តល់សំរាប់កុមារនូវបទពិសោធន៍ដ៏ប្រសើរដែលអាចធ្វើទៅបាន។

### កន្លែងគុណភាពទាំង៧នៃ QIAS

**1. ទំនាក់ទំនងបុគ្គលិកជាមួយកុមារ និងអ្នកធ្វើការដែលមានឋានៈដូចគ្នា** ការទាក់ទងគ្នាដោយមានការគោរព ហើយមានការយល់ដឹងដែលមិនចេះផ្លាស់ប្តូរ ហើយការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងបុគ្គលិក និងកុមារជួយជម្រុញផ្នែកសុខុមាលភាព សង្គម និងអារម្មណ៍។

**2. ដៃគូជាមួយគ្រួសារ** ភាពជាដៃគូរវាងបុគ្គលិក និងគ្រួសារត្រូវបានផ្តល់លក្ខណៈពិសេសដោយសារការប្រាស្រ័យទាក់ទងគ្នាយ៉ាងសកម្ម និងការពិគ្រោះយោបល់ដែលត្រូវបានធ្វើឡើងដោយបុគ្គលិក និងអ្នកគ្រប់គ្រង។

**3. ផែនការបង្កើតកម្មវិធី និងការប៉ាន់តម្លៃ** ការបង្កើតកម្មវិធីដែលមានប្រសិទ្ធិភាព គិតបញ្ចូលទាំងពត៌មានត្រឡប់មកពីគ្រប់អ្នកចូលរួមទាំងអស់ ដែលសំខាន់ជាងគេនោះគឺកុមារខ្លួនគេតែម្តង។

**4. បទពិសោធន៍ និងការរៀនសូត្ររបស់កុមារ** ដើម្បីឲ្យបានយល់ដឹងអំពីពិភពលោក កុមារត្រូវការបរិយាកាសមួយដែលមានការលើកទឹកចិត្តត្រូវបានរៀបចំឡើង ដោយមានការគិតគូរមានការសរសើរដោយទឹកមុខញញឹម ព្រមទាំងឲ្យមានការឆ្លុះបញ្ចាំងពីវប្បធម៌ផ្សេងៗ។

**5. ការមើលថែទាំ និងសុវត្ថិភាពដែលមានការគាំពារ** អ្នកគ្រប់គ្រង និងបុគ្គលិកចាត់ទុកសុវត្ថិភាពរបស់កុមារជាសំខាន់ទីមួយគ្រប់ពេលវេលា ហើយមានទម្រង់ការដើម្បីធានាសុវត្ថិភាពនេះ។

**6. សុខភាព ផ្នែកបំប៉នចំណីអាហារ និងសុខុមាលភាព** មណ្ឌលជំរុញឲ្យមានទម្រង់ការសុខុមាលភាពការបរិភោគប្រកបដោយសុខភាពល្អ ព្រមទាំងអនុវត្តវិធីអនាម័យដោយប្រសិទ្ធិភាពតាមរយៈការលាងសំអាតដៃ និងការចាក់ថ្នាំបង្ការរោគ។

**7. ការមើលគ្រប់គ្រងដើម្បីគាំទ្រគុណភាព** អ្នកគ្រប់គ្រងប្រតិបត្តិដោយប្រសិទ្ធិភាព ហើយមានសីលធម៌។

ដើម្បីទទួលយកពត៌មានបន្ថែមទៀតស្តីអំពីកន្លែងគុណភាពសូមអាន កូនសៀវភៅណែនាំនៃការអនុវត្តគុណភាពរបស់ *QIAS* (QIAS *Quality Practices Guide*) (2005)។

### តួនាទីរបស់គ្រួសារនៅក្នុង QIAS

QIAS លើកទឹកចិត្តមណ្ឌលមើលថែទាំកុមារពេញមួយថ្ងៃនីមួយៗ និងគ្រួសាររបស់ខ្លួនឲ្យធ្វើការរួមគ្នាដើម្បីបង្កើត ហើយពិនិត្យឡើងវិញនូវទស្សនៈគោលការណ៍ និងទម្រង់ការរបស់កិច្ចបំរើ។ ការទាំងនេះនឹងជួយធ្វើឲ្យមានរូបរាងដល់បទពិសោធន៍ដ៏សមរម្យ បែបនៃការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងបុគ្គលិក និងកុមារ។

QIAS លើកទឹកចិត្តគ្រួសារ និងសមាជិកសហគមន៍ឲ្យចូលប្រឡូកនៅក្នុងសកម្មភាពទាំងឡាយរបស់មណ្ឌល។ ការនេះនឹងជួយកុមារឲ្យបានយល់អំពីសហគមន៍របស់គេ និងបង្កើតជំនាញការផ្នែកសង្គមរបស់គេ។

វាមានសារសំខាន់ផងដែរដែលគ្រួសារអាចនិយាយដោយសេរីជាមួយអ្នកមើលថែទាំរបស់កូនខ្លួន និងបុគ្គលិកកិច្ចបំរើរបស់គេអំពីបញ្ហាទាំងឡាយដូចជាគោលការណ៍វិន័យអប់រំ អនាម័យ ដំណើរសិក្សា ការចាក់ថ្នាំបង្ការរោគ ការការពារកំដៅថ្ងៃ និងសុវត្ថិភាពរបស់កិច្ចបំរើ។

### របៀបរៀនដឹងច្រើនថែមទៀតអំពីការមើលថែទាំកុមារប្រកបដោយគុណភាព

NACA យកចិត្តទុកដាក់យ៉ាងក្រៃលែងដើម្បីជួយគ្រួសារក្នុងការរៀនដឹងច្រើនថែមទៀត អំពីការមើលថែទាំកុមារប្រកបដោយគុណភាព។ ពត៌មានស្តីអំពីការធានាលើគុណភាពមើលថែទាំកុមារ គឺអាចទទួលយកបាននៅតាមគេហទំព័ររបស់ NCAC។ ច្បាប់ចម្លងនៃការបោះពុម្ពផ្សាយ QA គួរតែមានផ្តល់ជូនផងដែរនៅតាមកិច្ចបំរើ។

គ្រួសារដែលមានកង្វល់អំពីគុណភាពនៃការមើលថែទាំដែលផ្តល់ដោយមណ្ឌលមើលថែទាំពេញមួយថ្ងៃ ត្រូវបានលើកទឹកចិត្តឲ្យពិភាក្សាអំពីបញ្ហាទាំងនេះជាមួយកិច្ចបំរើនោះ។ មណ្ឌលដែលមានគុណភាពនឹងមានទម្រង់ការដោះស្រាយបញ្ហា និងបណ្តឹងដែលច្បាស់លាស់ ហើយជាក់លាក់។ ប្រសិនបើលោកអ្នកបានលើកឡើងនូវកង្វល់ទាំងឡាយអំពីបញ្ហាគុណភាព ជាមួយមណ្ឌលមើលថែទាំពេញមួយថ្ងៃក៏ប៉ុន្តែគេនៅតែមិនទាន់បានដោះស្រាយកង្វល់របស់លោកអ្នកទេ NCAC មានទម្រង់ការដោះស្រាយការតវ៉ាដែលលោកអ្នកអាចទទួលយកច្បាប់ចម្លងបានពីគេហទំព័ររបស់យើង ឬដោយទូរស័ព្ទទៅ NCAC។

ដើម្បីទទួលយកពត៌មានបន្ថែមទៀតស្តីអំពីការមើលថែទាំកុមារ និងការជ្រើសរើសកិច្ចបំរើប្រកបដោយគុណភាពសូមទាក់ទងជាមួយ NCAC តាមទូរស័ព្ទលេខ **1300 136 554**។

**ពេលម៉ោងធ្វើការ:** ថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ<br>ម៉ោង៨.៣០ព្រឹក ទៅម៉ោង៥រសៀល<br>ម៉ោងនៅក្នុងរដ្ឋញូវសោវែល

**អាសយដ្ឋានផ្ញើ:** Level 3, 418a Elizabeth Street<br>Surry Hills Sydney NSW 2010

**ទូរស័ព្ទ:** 1300 136 554 **ទូរសារ:** (02) 8260 1901

**អ៊ីម៉ែល:** qualitycare@ncac.gov.au

**គេហទំព័រ:** www.ncac.gov.au

**កិច្ចបំរើបកប្រែភាសាតាមទូរស័ព្ទ** សំរាប់ការទូរស័ព្ទនៅក្នុងភាសាក្រៅពីភាសាអង់គ្លេស 131 450

**កិច្ចបំរើបញ្ជូនតទូរស័ព្ទ** សំរាប់អ្នកទូរស័ព្ទដែលមានភាពពិការក្នុងការនិយាយស្តី 131 677

### ពត៌មានទាក់ទងសំខាន់ឯទៀត

**ប្រាក់បំណាច់មើលថែទាំកុមារ** - ប្រាក់បំណាច់សំរាប់គ្រួសារដើម្បីជួយលើការចំណាយមើលថែទាំកុមារ។ ទូរស័ព្ទទៅការិយាល័យជំនួយគ្រួសារ (Family Assistance Office) លេខ 136 150 ឬ Centrelink ឬការិយាល័យមេឌីឃែរប្រចាំតំបន់របស់លោកអ្នក។

**ក្រសួងជំនួញត្រឹមត្រូវ និងកិច្ចការអ្នកប្រើប្រាស់** - ប្រសិនបើលោកអ្នកមានកង្វល់ទាំងឡាយស្តីអំពីថ្លៃមើលថែទាំកុមារ ឬកិច្ចសន្យាសូមទាក់ទងជាមួយក្រសួងប្រចាំរដ្ឋ និងដែនដីរបស់លោកអ្នក ដែលទទួលបន្ទុកផ្នែកជំនួញត្រឹមត្រូវ និងកិច្ចការអ្នកប្រើប្រាស់។

© National Childcare Accreditation Council Inc - June 2005